លេខៈ ធ-៧ ០០-៣៨ប្រក

# ប្រកាស
# ស្តីពី
# សាច់ប្រាក់ងាយស្រួលរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៣៩៨/ ៨៥ ចុះថ្ងៃទី ១០ មិនា ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## ស ំ រេ ច

**ប្រការ ១.-**

ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតទៅនេះហៅថា "ធនាគារ" ត្រូវអនុវត្តអោយបានតាមវិធានគ្រប់គ្រងក្នុងគោលបំណងធានាសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-**

ធនាគារត្រូវគណនាអនុបាតសាច់ប្រាក់ងាយស្រួលលើមូលដ្ឋាននៃរបាយការណ៍គណនេយ្យប្រចាំខែរបស់ខ្លួន ។

**ប្រការ ៣.-**

ភាគយកនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន ÷

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះ នៅពេលសមតុល្យនេះតំណាងអោយស្ថានភាពនៃអ្នកអោយខ្ចី

២- ចំណែកនៃការអោយខ្ចីនៅសល់រយៈពេលមិនលើសពី ១ ខែ( លើកលែងតែឥណទានចំពោះអតិថិជនដោយគ្មានកាលវសាន្ត ដូចជា ឥណទានលើសសមតុល្យ )

៣- បណ្ណ័រតនាគារក្នុងរយៈពេលនៅសល់មិនលើសពី ១ ខែ ។

## ប្រការ ៤.-

ភាគបែងនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន ÷

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះនៅពេលសមតុល្យនេះតំណាងអោយស្ថានភាពអ្នកខ្ចី

២- ៨០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និងវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលមានរយៈពេលនៅសល់មិនលើសពី ១ ខែ

៣- ៥០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និង វិញ្ញាបនប័ត្រប្រាក់បញ្ញើ ដែលមានរយៈពេលនៅសល់លើសពី ១ ខែ

៤- ៥០ ភាគរយនៃប្រាក់បញ្ញើសញ្ជ័យ

៥- ៦០ ភាគរយនៃប្រាក់បញ្ញើគ្មានកាលកំណត់ ។

## ប្រការ ៥.-

សមតុល្យសាច់ប្រាក់ស្មើនឹងផលសងរវាងសរុបខ្ទង់ឥណពន្ធ ជាមួយសរុបខ្ទង់ឥណទានដូចមានរៀបរាប់ខាងក្រោម ÷

**១- ខ្ទង់ឥណពន្ធ**

ក- សាច់ប្រាក់ និង មាស

ខ- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា

គ- ប្រាក់បញ្ញើនៅធនាគារផ្សេងៗ

ឃ- ចំណែកនៃការអោយខ្ចីទៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង ក្នុងរយៈពេលនៅសល់មិនលើសពី ១ខែ ( លើកលែងតែឥណទានដែលគ្មានកំណត់កាលវសាន) ។

**២- ខ្ទង់ឥណទាន**

- សមតុល្យឥណទាយីលើគណនីប្រាក់បញ្ញើគ្មានកាលកំណត់ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា

នៅធនាគារ ឬនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង

- ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងពីធនាគារផ្សេងដោយមានរយៈពេលនៅសល់មិនលើសពី ១ ខែ ។

សមតុល្យសាច់ប្រាក់ត្រូវបានចាត់ទុកថា តំណាងអោយស្ថានភាពអ្នកអោយខ្ចី នៅពេលណាសរុបខ្ទង់ឥណពន្ធកើនលើសសរុបខ្ទង់ឥណទាន ។ សមតុល្យសាច់ប្រាក់ត្រូវចាត់ទុកថាតំណាងអោយស្ថានភាពអ្នកខ្ចី នៅពេលណាសរុបខ្ទង់ឥណទានកើនលើសសរុបខ្ទង់ឥណពន្ធ ។

## ប្រការ ៦.-

នៅរៀងរាល់ពេល ធនាគារត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត១០០ ភាគរយ ។

## ប្រការ ៧.-

ធនាគារត្រូវធ្វើប្រតិវេទន៍ប្រចាំខែ ពីអនុបាតសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ស្របតាមគំរូដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញ ។

## ប្រការ ៨.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

## ប្រការ ៩.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទ និង ក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ច រៀងៗខ្លួន ។

## ប្រការ ១០.-

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០០

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"